# ក្រសួងមុខងារសាធារណៈ

## អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

# លទ្ធផលការងារ

## បញ្ហាប្រឈមនិងទិសដៅការងារឆ្នាំ២០១៦

# មាតិកា

១. សេចក្តីផ្តើម

២. លទ្ធផលការងារ

៣. បញ្ហាប្រឈម

៤. ទិសដៅបន្ត

# ១. សេចក្តីផ្តើម

- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុមានភារកិច្ចដឹកនាំ គ្រប់គ្រង និងសម្របសម្រួលកិច្ចការរដ្ឋបាលបុគ្គលិក ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋ និងផែនការ។
- ក្នុងរយៈពេល២ឆ្នាំកន្លះនៃការអនុវត្តការងាររបស់ខ្លួន អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុសម្រេចបានលទ្ធផលដូចខាងក្រោម៖

# ២. លទ្ធផលការងារ

## ២.១. ការគ្រប់គ្រងធនធានមនុស្ស

- ក្រសួងមុខងារសាធារណៈមានមន្ត្រីរាជការសរុបចំនួន ៨១៥នាក់(ស្ត្រី២១៤នាក់)
  - ថ្នាក់ជាតិចំនួន ៤៩៣នាក់(ស្ត្រី ១១៨នាក់)
  - ថ្នាក់ក្រោមជាតិចំនួន ៣២២នាក់(ស្ត្រី ៩៦នាក់)

## មន្ត្រីរាជការស៊ីវិលថ្នាក់ជាតិមានមុខតំណែងចាប់ពីអនុប្រធានការិយាល័យរហូតដល់ថ្នាក់អគ្គនាយក និងថ្នាក់ប្រហាក់ប្រហែល គិតត្រឹមខែមីនា ឆ្នាំ២០១៦




| | អគ្គនាយក | អគ្គនាយករង | អគ្គាធិការ | អគ្គាធិការរង | អធិការ | អគ្គលេខាធិការរង | ប្រធាននាយកដ្ឋាន | អនុប្រធាននាយកដ្ឋាន | ប្រធានអង្គភាពលទ្ធកម្ម | ប្រធានការិយាល័យ | អនុប្រធានការិយាល័យ |
|---|---|---|---|---|---|---|---|---|---|---|---|
| ស្រី | ០ | ៤ | ០ | ០ | ២ | ១ | ៣ | ២២ | ០ | ២២ | ២៦ |
| សរុប | ៦ | ១៤ | ១ | ៥ | ៧ | ២ | ២០ | ៩៥ | ១ | ៥៨ | ៦៧ |


មន្ត្រីរាជការស៊ីវិលមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ចាប់ពីថ្នាក់អនុប្រធាន
ការិយាល័យឡើងដល់ថ្នាក់ប្រធានមន្ទីរ គិតត្រឹមខែមីនា ឆ្នាំ២០១៦
ចំនួនមន្ត្រីរាជការស៊ីវិល
៦០
៤០
២០
0
ប្រធានមន្ទីរ
អនុប្រធានមន្ទីរ
ប្រធានការិយាល័យ
អនុប្រធានការិយាល័យ
ស្រី ១ ៧ ៩ ១២
សរុប ២៥ ៣៩ ៤២ ២៥


ភាគរយមន្ត្រីរាជការស៊ីវិលក្រសួងមុខងារសាធារណៈតាមភេទ
30%
70%
ប្រុស
ស្រី

## ២.២. ការអភិវឌ្ឍធនធានមនុស្ស

- ការបណ្តុះបណ្តាល និងសិក្ខាសាលាក្នុងប្រទេស ចំនួន ១៦៦៨នាក់
- ទស្សនកិច្ចសិក្សានៅបរទេសនិងកិច្ចប្រជុំអន្តរជាតិចំនួន ២១៧នាក់ ក្នុងនោះរួមមាន៖ ប្រទេស ចិន  ជប៉ុន ថៃ ម៉ាឡេស៊ី វៀតណាម អាហ្វ្រាបែហ្សង់ និងសឹង្ហបុរី
- ការចែករំលែកបទពិសោធន៍ផ្ទៃក្នុង ៣វគ្គ មានសិក្ខាកាម ១៦៥នាក់

# ២.៣. ការអភិវឌ្ឍស្ថាប័ន

## ក. អង្គភាពថ្នាក់ជាតិ

- ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមុខងារសាធារណៈ
- អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងមុខងារសាធារណៈ
- ប្រកាសលេខ៣១១៨ មស.ប្រក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាន និងអង្គភាពនានានៃអគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាននៃក្រសួងមុខងារសាធារណៈ
- កំពុងរៀបចំនិងដាក់ឱ្យដំណើការប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិច។

# ២.៣. ការអភិវឌ្ឍស្ថាប័ន (ត)

## ខ. អង្គភាពថ្នាក់ក្រោមជាតិ

- ប្រកាសលេខ ១៩៧៩ មស.នក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត
- មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត
  - ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ
  - ការិយាល័យក្របខណ្ឌនិងបណ្តុះបណ្តាល
  - ការិយាល័យត្រួតពិនិត្យរដ្ឋបាលនិងបៀវត្ស

## ២.៤. ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

- បានរៀបចំតបណ្តាញ Network និងបណ្តាញ Server ថ្មី
- សាងសង់អគារទីស្តីការក្រសួងចំនួន០១ខ្នងមានកំពស់០៦ជាន់
- សាងសង់អគារមន្ទីរមុខងារសាធារណៈខេត្តចំនួន០៣៖ ខេត្តរតនគិរី ខេត្តស្វាយរៀង និងខេត្តកំពង់ចាម
- ជួសជុលអគារមន្ទីរចំនួន០៨ (ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តកោះកុង ខេត្តប៉ៃលិន ខេត្តកំពង់ស្ពឺ និងខេត្តតាកែវ)
- បានទិញដីនិងអគារសម្រាប់មន្ទីរមុខងារសាធារណៈខេត្តព្រៃវែង
- បានសាងសង់អគារប្រជុំមួយខ្នងមាន០២បន្ទប់
- បានរៀបចំចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ទាំងដីនិងសម្ភារបរិក្ខាសម្រេចបាន១០០% និងបានរៀបចំធ្វើបច្ចុប្បន្នភាពទ្រព្យសម្បត្តិរដ្ឋ ឆ្នាំ២០១៥ រួចរាល់ជាស្ថាពរ។

## ២.៥. ការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បានជំរុញការអនុវត្តគោលនយោបាយ ស្តីពីវិមជ្ឈការហិរញ្ញវត្ថុរយៈពេលមធ្យម និងរយៈពេលវែងនៅអង្គភាពនានាចំណុះក្រសួងមុខងារសាធារណៈ
- បានបង្កើតក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងមុខងារសាធារណៈ
- បានរៀបចំនិងដាក់ឱ្យអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣របស់ក្រសួងមុខងារសាធារណៈ (MAP3) ២០១៦-២០១៨
- បានផ្សព្វផ្សាយ និងបណ្តុះបណ្តាលផែនការយុទ្ធសាស្ត្រថវិកា ថវិកាកម្មវិធី និងអង្គភាពថវិកា។

# ៣. បញ្ហាប្រឈម

ក្រសួងមុខងារសាធារណៈទើបបង្កើតថ្មី ក្នុងការអនុវត្តការងារនៅជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចជា៖

- ធនធានមនុស្សមានជំនាញចំរុះ(ជំនាញទំនាក់ទំនងការងាររបស់មន្ត្រីមួយចំនួន នៅថ្នាក់ក្រោមជាតិ នៅមានកម្រិត)
- បរិស្ថានការងារមិនទាន់សមស្រប (ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅមិនទាន់គ្រប់តាមតម្រូវការ)។

# ៤. ទិសដៅការងារបន្ត

- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាដល់មន្ទីរ អង្គភាពចំណុះក្រសួងមុខងារសាធារណៈ
- ពង្រឹងការគាំទ្រ និងសម្របសម្រួលកិច្ចការទូទៅ
- បន្តពង្រឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងទ្រព្យសម្បត្តិរដ្ឋ
- ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យានៃក្រសួងមុខងារសាធារណៈ
- រៀបចំនិងដាក់ឱ្យអនុវត្តអង្គភាពថវិកា និងថវិកាកម្មវិធីឆ្នាំ២០១៧។

# សូមអរគុណចំពោះការយកចិត្តទុកដាក់!